គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)
Committee for Free and Fair Elections in Cambodia (COMFREL)
ទីស្នាក់ការកណ្តាល ៖ ផ្ទះ១៣៨ ផ្លូវ១២២ សង្កាត់ទឹកល្អក់១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Central Office: #138, St 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA. P.O.Box 1145,
Tel: (855) 23 884 150 Fax: (855) 23 883 750 E-mail: comfrel@online.com.kh, website : www.comfrel.org

ខុមហ្វ្រែល អ្នកឃ្លាំមើល / អត្ថបទលេខ ៩០

ថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ២០១០

# ការចុះឈ្មោះ និងបញ្ជីឈ្មោះអ្នកបោះឆ្នោត នៅតែចោទជាបញ្ហាសម្រាប់ការបោះឆ្នោតនៅកម្ពុជា

គោលបំណងចំបងនៃប្រព័ន្ធចុះឈ្មោះអ្នកបោះឆ្នោត គឺដើម្បីដាក់កម្រិតការប្រើប្រាស់សិទ្ធិដើម្បីគូសសន្លឹកឆ្នោត និងដើម្បីធានាថា មានត្រឹមតែពលរដ្ឋដែលច្បាប់បានផ្តល់អំណាចឲ្យទើបមានសិទ្ធិ និងអំណាចដើម្បីបោះឆ្នោត ហើយពួកគេអាចបោះឆ្នោតត្រឹមតែម្តងគត់ក្នុងមួយលើក។ បញ្ជីចុះឈ្មោះបោះឆ្នោតអាចមិនសំខាន់ដើម្បីសម្រេចបានគោលបំណងនោះ តែពួកគេស្ទើរតែទទួលស្គាល់ជាសកល និងជាទ្រឹស្តីដែលចូលចិត្តជាងគេនៅសហរដ្ឋអាមេរិក លើកលែង រដ្ឋណសដាកូតា (North Dakota) ដែលមិនមានការចុះឈ្មោះបោះឆ្នោតបែរជាពឹងផ្អែកលើឯកសារកំណត់អត្តសញ្ញាណ ឬលិខិតបញ្ជាក់ផ្សេងៗ។ បញ្ជីចុះឈ្មោះបោះឆ្នោត អាចនឹងប្រើប្រាស់ក្នុងគោលបំណងដទៃផងដែរ ដូចជា មន្ត្រីរដ្ឋបាលបោះឆ្នោតអាចប្រើវាដើម្បីជួយកំណត់ទីតាំង ដែលប្រសើរបំផុតសម្រាប់ការតាំងការិយាល័យបោះឆ្នោត ចំនួនស្ថានីយបោះឆ្នោត ចំនួនបុគ្គលិកស្ថានីយបោះឆ្នោត ចំនួនអ្នកទៅបោះឆ្នោត។ គណបក្សនយោបាយ និងបេក្ខជន អាចប្រើប្រាស់បញ្ជីឈ្មោះអ្នកបោះឆ្នោត សម្រាប់សកម្មភាពឃោសនាដោយផ្ទាល់។ល។ តែក៏មានរដ្ឋមួយចំនួន បានរឹតបន្តឹងចំពោះការប្រើប្រាស់បញ្ជីឈ្មោះអ្នកបោះឆ្នោតដែលបានផ្សាយជាសាធារណៈ សម្រាប់គោលបំណងនយោបាយបែបនេះផងដែរ។ ទោះបីជាយ៉ាងណា គំរូនៃការចុះឈ្មោះអ្នកបោះឆ្នោតត្រូវបានអនុវត្ត ហើយអភិវឌ្ឍដើម្បីថែទាំ ត្រួតពិនិត្យ និងបម្រើឲ្យផលប្រយោជន៍ពលរដ្ឋម្ចាស់ឆ្នោតជាសំខាន់។

ការបង្កើត និងអនុវត្តប្រព័ន្ធចុះឈ្មោះអ្នកបោះឆ្នោត វានឹងចាំបាច់ដើម្បីទទួលទិន្នន័យដែលពាក់ពន្ធ័ដើម្បីកំណត់ តើមានអ្នកចុះឈ្មោះស្របច្បាប់ប៉ុន្មាននាក់ពិតប្រាកដ ? ប្រព័ន្ធនៃការចុះឈ្មោះអ្នកបោះឆ្នោតមានភាពខុសប្លែកជាពីរប្រភេទ គឺ ប្រព័ន្ធចុះឈ្មោះដែលផ្តល់ករណីយកិច្ចឲ្យប្រជាពលរដ្ឋច្រើនដើម្បីទៅចុះឈ្មោះ និងពិនិត្យឈ្មោះជាទៀតទាត់ តែប្រព័ន្ធមួយទៀត ផ្តល់ករណីយកិច្ច និងការទទួលខុសត្រូវទៅរដ្ឋច្រើន ដែលត្រូវធានាថា អ្នកបោះឆ្នោតត្រូវបានបញ្ចូលដោយស្វ័យប្រវត្តិទៅក្នុងបញ្ជី នៅពេលពួកគេឈានដល់អាយុបោះឆ្នោតស្របច្បាប់ និងផ្តល់ព័ត៌មានទៅដល់ប្រជាពលរដ្ឋទាំងនោះ។

នៅកម្ពុជា ប្រពន្ធ័ចុះឈ្មោះ និងបញ្ជីឈ្មោះអ្នកបោះឆ្នោត បានបង្កើតឡើងនូវបន្ទុកករណីយកិច្ចទៅដល់ប្រជាពលរដ្ឋ។ ថ្មីៗនេះវាបានបង្កបញ្ហា និងធ្វើឲ្យមានការបាត់បង់នូវសិទ្ធិអ្នកបោះឆ្នោតរាប់សែននាក់ ក្នុងអំឡុងពេលបោះឆ្នោតកាលពីឆ្នាំ ២០០៧ និង២០០៨

គណៈកម្មាធិការនាយក
Board of Directors

១.លោក ធន សារាយ
Mr.Thun Saray
ប្រធានគណៈកម្មាធិការនាយកនិងជាប្រធាន ADHOC

២.លោក សុក សំអឿន
Mr.Sok Sam Oeun
អនុប្រធានគណៈកម្មាធិការនាយកនិងជានាយក CDP

៣.លោក យឹម ប៉ូ
Mr.Yim Po
អគ្គហេរញ្ញិកនិងជាទីប្រឹក្សា CCPCR

៤.អ្នកស្រី ស៊ុន ចាន់សែន
Miss.Sun Chansen
ប្រធាន KYA

៥.លោក យង់ គឹមអេង
Mr.Yongg Kim Eng
នាយកPDP-Center

៦.លោក មុំ សារិន
Mr.Mom Sarin
នាយក HRCDO

៧.លោកស្រីទីវសារាយេត
Mrs.Tiv Sarayet
សហនាយកាWMC

៨.លោកស្រី ពឹង យក់ហៀប
Mrs.Peng Yok Hiep
សមាជិក ជាឥស្សរជន Dignitary

៩.លោក គឹម សុវណ្ណ
Mr.Kim Sovann
នាយក VIGILANCE

១០.លោក សឺន សែត
Mr.Sen Set
សមាជិក ជាឥស្សរជន Dignitary

១១.នាយិកា CWCC(NA)

១២.នាយក LAC(NA)

កន្លងទៅនេះ។ រហូតមកដល់បច្ចុប្បន្ន បញ្ហានេះនៅតែជាចំណោទ ក្តីបារម្ភ និងក្លាយជាប្រធានបទដ៏សំខាន់សម្រាប់ការត្រៀមរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ឆ្នាំ២០១២ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ ២០១៣ ខាងមុខនេះ ហើយទាមទាឲ្យមានការកែលម្អជាបន្ទាន់។

ជារៀងរាល់ឆ្នាំ ចាប់ពីថ្ងៃទី ០១ ដល់ថ្ងៃទី ២០ ខែតុលា នៅកម្ពុជា មានព្រឹត្តិការណ៍ចុះឈ្មោះអ្នកបោះឆ្នោត និងធ្វើបច្ចុប្បន្នកម្មបញ្ជីឈ្មោះអ្នកបោះឆ្នោត ដែលតម្រូវឲ្យ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចាត់ចែងរៀបចំ ស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។ ចាប់តាំងពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ ២០០៧ មក ភាពជឿជាក់របស់ក្រុមអ្នកពាក់ព័ន្ធការងារបោះឆ្នោតទៅលើបញ្ជីបោះឆ្នោតមានការថយចុះយ៉ាងខ្លាំង។ នៅក្នុងអំឡុងពេលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ ២០០៨ ការចុះឈ្មោះអ្នកបោះឆ្នោត និងការសម្អាតបញ្ជីបោះឆ្នោតមានភាពមិនប្រក្រតីមួយចំនួន បើទោះបីមានការខិតខំប្រឹងប្រែងធ្វើឲ្យដំណើរការនេះមានភាពប្រសើរឡើងក៏ដោយ។

ថ្មីៗនេះ ថ្ងៃទី ៣០ វិច្ឆិកា ឆ្នាំ២០១០ មន្ត្រីជាន់ខ្ពស់ គ.ជ.ប បានថ្លែងក្នុងសន្និសីទសារព័ត៌មានមួយថា អំឡុងពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះអ្នកបោះឆ្នោត ឆ្នាំ២០១០ មានបណ្តឹងចំនួន ២២ ដែលបានប្តឹងដោយប្រជាពលរដ្ឋ និងតំណាងគណបក្សនយោបាយ ដែលកម្មវត្ថុនៃបណ្តឹងភាគច្រើនបានចោទ ប្រកាន់ទៅលើសមាជិកក្រុមប្រឹក្សាសង្កាត់ថា រំលោភច្បាប់ និងសេចក្តីណែនាំរួមរវាង គ.ជ.ប និងក្រសួងមហាផ្ទៃ និងមួយចំនួនទៀតទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង។ តាមរបាយការណ៍មួយរបស់ គ.ជ.ប ចេញផ្សាយថ្ងៃទី ៣០ ខែវិច្ឆិកា ដដែល បានបង្ហាញថា គិតចាប់ពីថ្ងៃទី ១ ដល់ថ្ងៃទី ២៣ ខែតុលា ឆ្នាំ២០១០ មានអ្នកចុះឈ្មោះថ្មីចំនួន ៣៨៩ ៧៣០ នាក់ នៅទូទាំង ១៦២១ ឃុំ សង្កាត់ ច្រើនជាងចំនួនប៉ាន់ប្រមាណពលរដ្ឋត្រូវចុះឈ្មោះថ្មីមានចំនួន ៣១៩១៩៣ នាក់ ខណៈដែលឈ្មោះប្រហែល ១៧៦ ១៩៩ នាក់ ត្រូវបានលុបចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោត និងប្រមាណ ៣៧ ៦៨០ នាក់ ត្រូវបានកែតម្រូវ។ ចំនួនអ្នកបោះឆ្នោត ត្រូវបានកែតម្រូវនេះ មិនអាចបង្កើនគុណភាពបញ្ជីឈ្មោះអ្នកបោះឆ្នោត ឆ្នាំ ២០១០ មានចំនួនជាង ៨ លាន ៩ សែននាក់នោះទេ។

តាមរបាយការណ៍សវនកម្មរបស់ ខុមហ្វ្រែល បញ្ជីឈ្មោះអ្នកបោះឆ្នោតឆ្នាំ ២០០៩ អាចមានភាពមិនត្រឹមត្រូវនៃទិន្នន័យរបស់អ្នកបោះឆ្នោត ដែលអាចបង្កឲ្យមានការបាត់បង់សិទ្ធិអ្នកបោះឆ្នោត ១ ៥០០ ០០០ នាក់ ក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតឆ្នាំ ២០០៩ ដែលមានទិន្នន័យមិនប្រក្រតី ដូចជា ឈ្មោះស្ទួន ឈ្មោះខ្មោច... ។ នៅក្នុងនីតិវិធីក្នុងការចុះឈ្មោះបោះឆ្នោត សម្រាប់អ្នកផ្លាស់ទីលំនៅ បង្ហាញថា អ្នកមានសិទ្ធិបោះឆ្នោតដែលបានផ្លាស់ប្តូរទីលំនៅ ទៅទីលំនៅថ្មី ៤៣.៨៥ % ត្រូវការឲ្យមន្ត្រីចុះឈ្មោះទៅចុះឈ្មោះឲ្យដល់ភូមិដែលពលរដ្ឋត្រូវគេបណ្តេញចេញមកតាំងទីនៅលើថ្មីនោះ។ ៣៦.៨៩ % មានយោបល់ថា ឲ្យរក្សាដូចបច្ចុប្បន្នតាមនីតិវិធីរបស់ គ.ជ.ប។ សម្រាប់ហេតុផល ដែលថា ត្រូវចុះឈ្មោះឲ្យដោយមិនត្រូវទាមទារ ឯកសារបញ្ជាក់ទីលំនៅ គឺមានតែ ៧.៧៩ % ទេ ក្រៅពីនោះ គឺមិនមានហេតុផល និងយោបល់អ្វីទាំងអស់។ ៧២.១៣ % នៃប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោត និងរស់នៅទីលំនៅថ្មី បានចុះឈ្មោះបោះឆ្នោត

នៅកន្លែងកំពុងរស់នៅ ក្នុងចំណោមនោះមាន ១១.៨៩ % ត្រូវបានរកឃើញឈ្មោះនៅក្នុងបញ្ជីបោះឆ្នោត ២០០៩ ជាពិសេសឈ្មោះ អាសយដ្ឋាន ភេទ និងអាយុ ត្រឹមត្រូវដូចឯកសារ ដែលគាត់មាន និងយកទៅចុះឈ្មោះ ឬទៅបោះឆ្នោត។ ក្នុងនោះមាន ៦៣.១១ % មានភាពត្រឹមត្រូវមិនពេញលេញ មានន័យថា យ៉ាងហោចណាស់ក្នុងចំណោមឈ្មោះ អាសយដ្ឋាន ភេទ ឬអាយុមានចំណុចណាមួយ ខុសគ្នារវាងឯកសារដែលគាត់មាន ជាមួយបញ្ជីឈ្មោះបោះឆ្នោត ២០០៩ តែគាត់អាចបោះបានដោយ ផ្អែកលើសេចក្តីណែនាំរបស់ គជប។ ចំណែក ២៥ % ទៀត គឺមិនអាចស្វែងរកឃើញព័ត៌មានអ្វីទាំងអស់ នៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត ២០០៩ មានន័យថាគាត់ត្រូវបាត់បង់សិទ្ធិក្នុងការបោះឆ្នោតទាំងស្រុងតែម្តង។

តាមការស្រាវជ្រាវមួយ ពីការចូលរួមរបស់ស្ត្រីពិការក្នុងវិស័យនយោបាយ ដែលបានអង្កេតទៅលើស្ត្រីពិការនៅក្នុងខេត្តកំពង់ស្ពឺ ខេត្តកំពង់ចាម និងរាជធានីភ្នំពេញ ក្នុងឆ្នាំ ២០១០ នេះ ខុមហ្វ្រែល រកឃើញថា ឧបសគ្គចំបងនៃការចុះឈ្មោះបោះឆ្នោត និងការចូលរួមបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្ររបស់ស្ត្រីពិការ បណ្តាលមកពីការមិនលើកទឹកចិត្ត និងអាកប្បកិរិយារើសអើងនៅថ្នាក់មូលដ្ឋាន កង្វះខាតភាពងាយស្រួលក្នុងការចុះឈ្មោះបោះឆ្នោត កង្វះលទ្ធភាពធ្វើដំណើរ និងការដឹកជញ្ជូន កង្វះលទ្ធភាពក្នុងការទទួលបានព័ត៌មាន និងចំណេះដឹងពាក់ពន្ធ័នឹងការចុះឈ្មោះ។ ជាលទ្ធផល ២៩ % នៃស្ត្រីពិការទាំងនោះ បានឆ្លើយតបថា ពួកគេមិនមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតឆ្នាំ ២០០៨។

ទាំងគណបក្សនយោបាយមិនកាន់អំណាច និងអង្គការសង្គមស៊ីវិលដែលធ្វើការពាក់ព័ន្ធនឹងការបោះឆ្នោត បានធ្វើការកត់សម្គាល់ទៅលើការអនុវត្តការងាររបស់ស្មៀនឃុំ សង្កាត់ និងមេឃុំចៅ សង្កាត់ខ្លះ ក្នុងការចុះឈ្មោះ និងលុបឈ្មោះអ្នកបោះឆ្នោត ថាមានភាពលម្អៀង ឬមានការរើសអើងទៅលើអ្នកបោះឆ្នោត ដែលគេអាចដឹងបានថា មាននិន្នាការមិនគាំទ្រគណបក្សកាន់អំណាច។ ការដែលតម្រូវឲ្យមានអ្នកបោះឆ្នោតត្រូវទៅពិនិត្យបញ្ជីឈ្មោះជារៀងរាល់ឆ្នាំនេះ ក៏ជាបញ្ហាដែលបានលើកឡើងថា ជាការដាក់ការទទួលខុសត្រូវទៅលើអ្នកបោះឆ្នោត ជាជាងទៅលើអ្នកអនុវត្តការចុះឈ្មោះបោះឆ្នោត (មេឃុំ ចៅសង្កាត់ ស្មៀនឃុំ សង្កាត់ និងគជប) ក្នុងករណីមានការបាត់បង់សិទ្ធិបោះឆ្នោត។ មានប្រជាពលរដ្ឋជាច្រើន ដែលត្អូញត្អែរថា បើទោះបីជាពួកគាត់បានស្នើឲ្យកែតម្រូវឈ្មោះ ឬទិន្នន័យខ្លះ ប៉ុន្តែឈ្មោះរបស់គាត់ និងទិន្នន័យនោះនៅតែខុសដដែល។ តាមរបាយការណ៍ស្រាវជ្រាវមួយរបស់អង្គការ ខុមហ្វ្រែល បានបង្ហាញថានៅក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ ២០០៨ មានប្រជាពលរដ្ឋខ្មែរ ដែលមានសិទ្ធិបោះឆ្នោតប្រហែល ៤៥០.០០០ នាក់ (ភាគច្រើននៃអ្នកទាំងនោះ បានបោះឆ្នោតនៅក្នុងឆ្នាំ ២០០៣ និង២០០៧) ពុំបានបោះឆ្នោតដោយសារបញ្ហាផ្សេងៗ ដែលពួកគេរកឈ្មោះមិនឃើញ ឬពុំអាចរកការិយាល័យបោះឆ្នោតឃើញ។ ទន្ទឹមនឹងនេះ គណបក្សនយោបាយមួយចំនួនមានការខ្វល់ខ្វាយទៅលើភាពមិនប្រក្រតីទាក់ទិនទៅនឹងការចេញទម្រង់ ១០១៨ (ឯកសារបញ្ជាក់អត្តសញ្ញាណសម្រាប់ការបោះឆ្នោត)។ នៅក្នុងករណីនេះ មានការចោទប្រកាន់ពីសំណាក់គណបក្សប្រឆាំងថា កន្លងមកមេឃុំ ចៅសង្កាត់ មួយចំនួនបានចេញទម្រង់ ១០១៨ ទៅដល់អ្នកដែល

មិនមានសិទ្ធិបោះឆ្នោត។ ករណីនេះដែរ គជប ក៏មិនមានលទ្ធភាពក្នុងការបង្ហាញពីចំនួន ទម្រង់ ១០១៨ ដែលបានចេញនៅក្នុងពេលបោះឆ្នោតឆ្នាំ ២០០៨។

ក្នុងកិច្ចប្រជុំប្រកាសលទ្ធផលបណ្ដោះអាសន្នមួយនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះអ្នកបោះឆ្នោតឆ្នាំ ២០១០ នៅទីស្នាក់ការកណ្ដាល គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី ១២ ខែតុលា តំណាងរាស្ត្រមួយចំនួន តំណាងគណបក្សនយោបាយ និងតំណាង គ.ជ.ប សុទ្ធតែបានបង្ហាញពីឆន្ទៈក្នុងការកែប្រែប្រពន្ធ័រៀបចំបញ្ជីចុះឈ្មោះអ្នកបោះឆ្នោត ដើម្បីជៀសវាងការបាត់ឈ្មោះ ស្រង់ស្ទួនឈ្មោះ និងសម្រាលពេលវេលាពលរដ្ឋក្នុងការពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោតច្រើនដង។ អនុសាសន៍ដែលបានលើកឡើងថា គួររកមធ្យោបាយកុំព្យូទ័រនីយកម្ម សម្រាប់ការចុះឈ្មោះ និងការផលិតបញ្ជីឈ្មោះនេះ។ គ.ជ.ប បានបកស្រាយថា ស្ថានភាពបច្ចុប្បន្ននេះ ប្រទេសកម្ពុជាមិនអាចកែប្រែ ប្រពន្ធ័បញ្ជីចុះឈ្មោះអ្នកបោះឆ្នោតឲ្យស្របតាមបច្ចេកវិទ្យាជឿនលឿនបានទេ ព្រោះ គ.ជ.ប ខ្វះខាតថវិកាទិញសម្ភារៈទំនើប។ មានការខិតខំរិះរកយោបល់ និងផ្ដល់អនុសាសន៍ ដោយគណៈកម្មាធិការ ខុមហ្វ្រែល សហការជាមួយនឹងសាខាបណ្ដាញនៃអង្គការសង្គមស៊ីវិល និងស្ថាប័នពាក់ពន្ធ័មួយចំនួន បានប្រមូលព័ត៌មាន និងមតិតាមរយៈការស្រាវជ្រាវ សវនកម្ម សិក្ខាសាលា និងវេទិកាស្ដីពី ការបោះឆ្នោត និងប្រជាធិបតេយ្យជាច្រើន ដើម្បីពិភាក្សារកអនុសាសន៍ដើម្បីកែលម្អការបោះឆ្នោត។ មានអ្នកជំនាញការអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិ បានផ្ដល់យោបល់ថា កម្ពុជាអាចផ្លាស់ប្ដូរប្រព័ន្ធចុះឈ្មោះបោះឆ្នោត ដែលអាចគ្រប់គ្រងទិន្នន័យ និងអត្តសញ្ញាណអ្នកបោះឆ្នោតច្បាស់លាស់ ដូចជាមានរូបថត និងជីវសាស្ត្រ (អាចយកតាមម៉ូឌែល ប្រទេសបង់ក្លាដេស ប្រទេសថៃ ប្រទេសហ្វីលីពីន ប្រទេសម៉ាឡេស៊ី) មានការប៉ាន់ប្រមាណនៃការដូរប្រពន្ធ័នេះដែលត្រូវការថវិកាប្រហែល ១០ លាន ដុល្លាសហរដ្ឋ។

អនុសាសន៍មួយទាក់ទិននឹងការលប់ឈ្មោះថា ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវមានឯកសារបញ្ជាក់គ្រប់គ្រាន់មុននឹងធ្វើបច្ចុប្បន្នភាព ឬលុបឈ្មោះអ្នកបោះឆ្នោតដែលផ្លាស់ប្ដូរទីលំនៅទៅឃុំ សង្កាត់ផ្សេង ឬស្លាប់។ ដោយសារតែការបោះឆ្នោត ត្រូវបានធ្វើឡើងជារៀងរាល់ ៥ ឆ្នាំ ដូចនេះ នៅក្នុងអំឡុងឆ្នាំបោះឆ្នោត គជប ត្រូវសហការជាមួយប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដែលមានសមាសភាពចំនួន ពីរូប (មកពីគណបក្សនយោបាយផ្សេងគ្នា) ស្មៀនឃុំ សង្កាត់ និងអាជ្ញាធរមូលដ្ឋាន ផ្សេងៗទៀត ត្រូវទទួលខុសត្រូវក្នុងការរៀបចំការចុះឈ្មោះអ្នកបោះឆ្នោត និងធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោតពិសេសនេះ គួរបន្ថែមដល់ ១២០ ថ្ងៃ ដើម្បីឲ្យប្រជាពលរដ្ឋមានពេលវេលាច្រើនចុះឈ្មោះបោះឆ្នោត និងពិនិត្យកែតម្រូវទិន្នន័យក្នុងបញ្ជីបោះឆ្នោត។ គជប គួរតែងតាំងបុគ្គលិករបស់ខ្លួនជាប្រធាន/អ្នកគ្រប់គ្រងក្នុងការចុះឈ្មោះអ្នកបោះឆ្នោតថ្នាក់ឃុំ សង្កាត់។ យុទ្ធនាការថ្នាក់ជាតិត្រូវតែធ្វើឡើងដើម្បីផ្សព្វផ្សាយ និងជម្រុញអ្នកបោះឆ្នោតឲ្យទៅចុះឈ្មោះបោះឆ្នោត ពិនិត្យឈ្មោះ និងកែតម្រូវព័ត៌មានក្នុងបញ្ជីបោះឆ្នោតក្នុងករណីខុសពីឯកសារអត្តសញ្ញាណពិតប្រាកដរបស់ខ្លួន។ យុទ្ធនាការនេះអាចធ្វើឡើងដោយ គជប គណបក្សនយោបាយរាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល ឬ/និងភាគីពាក់ព័ន្ធការបោះឆ្នោតនានា។ លើសពីនេះទៀត អង្គការសង្កេតការណ៍បោះឆ្នោត និងគណបក្សនយោបាយ

អាចធ្វើការអង្កេតទៅលើដំណើរការចុះឈ្មោះអ្នកបោះឆ្នោត និងការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោតនៅក្នុងឆ្នាំពិសេសនេះ។

អង្គការមិនមែនរដ្ឋាភិបាលដែលជាស្ថាប័នឯករាជ្យ ត្រូវបន្តធ្វើសវនកម្មបញ្ជីបោះឆ្នោត ដើម្បីផ្តល់ព័ត៌មានពីភាពត្រឹមត្រូវនៃបញ្ជីបោះឆ្នោត មុននឹងមានការចុះឈ្មោះបោះឆ្នោត និងការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោតពិសេស។ ព័ត៌មាននៅក្នុងបញ្ជីបោះឆ្នោត (ឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើត) គួរតែត្រូវធ្វើការផ្ទៀងផ្ទាត់ជាមួយនឹងអត្តសញ្ញាណបណ្ណដែលចេញដោយក្រសួងមហាផ្ទៃ។ គជប ត្រូវប្រើព័ត៌មាននេះដើម្បីផ្ទៀងផ្ទាត់ និងធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត។ ទោះបីជាយ៉ាងណា គជប ត្រូវធ្វើទំនាក់ទំនងជាមួយអ្នកចុះឈ្មោះបោះឆ្នោតដែលព័ត៌មានរបស់គាត់ត្រូវការកែតម្រូវ ឬធ្វើបច្ចុប្បន្នភាព។

ប្រសិនបើការធ្វើសវនកម្មបញ្ជីបោះឆ្នោតរកឃើញថា ភាពត្រឹមត្រូវនៃបញ្ជីបោះឆ្នោតនៅក្រោម ៩០ % (ទិន្នន័យមិនត្រឹមត្រូវដូចជាឈ្មោះស្ទួន និងឈ្មោះខ្មោច) គជប ដោយសហការជាមួយប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដោយមានចំនួនពីររូប (មកពីគណបក្សនយោបាយផ្សេងគ្នា) ស្មៀនឃុំ សង្កាត់ និងអាជ្ញាធរផ្សេងៗទៀត ត្រូវទទួលខុសត្រូវសម្អាតបញ្ជីបោះឆ្នោត។ នីតិវិធីនៃការសម្អាតបញ្ជីឆ្នោត ត្រូវតែធ្វើការកែប្រែ។ គជប គួរតែប្រើប្រាស់បញ្ជីបោះឆ្នោតដែលបានប្រើក្នុងការបោះឆ្នោតចុងក្រោយ ហើយរកឈ្មោះអ្នកដែលមិនបានបោះឆ្នោត។ ដូចនេះ គជប ត្រូវផ្តោតការយកចិត្តទុកដាក់តែជនដែលមិនបានបោះឆ្នោតដែលធ្វើឡើងក្រោយគេបានហើយ ដោយមិនបាច់គិតពីអ្នកដែលបានបោះឆ្នោតនោះទេ។

អ្នកបោះឆ្នោតម្នាក់ៗ ត្រូវតែមានបណ្ណព័ត៌មានបោះឆ្នោតដើម្បីដោះស្រាយឧបសគ្គធំៗនានា នៅការិយាល័យបោះឆ្នោតដែលជួបបញ្ហារកឈ្មោះ ឬការិយាល័យបោះឆ្នោតរបស់ខ្លួនមិនឃើញ។ ប័ណ្ណព័ត៌មានអ្នកបោះឆ្នោតត្រូវបានផលិតដោយមានអ៊ុតផ្លាស្ទិក ហើយត្រូវមានព័ត៌មានអ្នកបោះឆ្នោតជាពិសេសការិយាល័យ និងមណ្ឌលបោះឆ្នោត «ជាអចិន្ត្រៃយ៍»។ អ្នកបោះឆ្នោតត្រូវរក្សាបណ្ណព័ត៌មានទុកដូចជា ប័ណ្ណដទៃទៀតដែរ។ ព័ត៌មានអ្នកបោះឆ្នោត អាចដូរបាន ក្នុងករណីដែលអ្នកបោះឆ្នោតផ្លាស់ប្តូរលំនៅដ្ឋានទៅឃុំផ្សេងទៀត ឬការិយាល័យបោះឆ្នោត។ គជប ត្រូវរៀបចំបញ្ជីបោះឆ្នោតអាចដូរបាន ក្នុងករណីដែលអ្នកបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាដែលមានបញ្ហា (ឧទាហរណ៍ រៀបតាមអក្ខរក្រម ឬលេខកូដអ្នកបោះឆ្នោត លេខកូដការិយាល័យ) ហើយការផ្លាស់ប្តូរទាំងនេះ ត្រូវតែជូនដំណឹងដល់អ្នកបោះឆ្នោត។ ជាងនេះទៀត ដោយឧបសគ្គចម្បងនានាដែលនាំឲ្យមិនបានបោះឆ្នោត គឺទាក់ទងនឹងការរកឈ្មោះ ឬការិយាល័យមិនឃើញ(៥៦%នៃចម្លើយ) ហើយដោយគិតទៅលើអ្នកបោះឆ្នោតប្រមាណ ៩ % ដែលមិនបានទទួលប័ណ្ណព័ត៌មានអ្នកបោះឆ្នោត នោះការចែកប័ណ្ណព័ត៌មានគួរតែត្រូវធ្វើឡើងដោយ គជប ដោយសហការ ជាមួយប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដោយមានចំនួនពីររូប (មកពីគណបក្សនយោបាយផ្សេងគ្នា) ស្មៀនឃុំ សង្កាត់ និងអាជ្ញាធរមូលដ្ឋានផ្សេងៗទៀត ដែលអ្នកបោះឆ្នោតចង់ឲ្យធ្វើកិច្ចការនេះ។ ហើយត្រូវធានាថាអ្នកបោះឆ្នោតដែលបានចុះឈ្មោះទាំងអស់ ត្រូវបានទទួលប័ណ្ណព័ត៌មានអ្នកបោះឆ្នោត។

ដោយឡែក នៅថ្ងៃទី ១៥ ខែមេសា ឆ្នាំ២០១០ គជប និងក្រសួងមហាផ្ទៃ ក៏បានរួមគ្នាបង្កើតក្រុមការងារបច្ចេកទេសរួមចម្រុះ ដើម្បីពិនិត្យលទ្ធភាពក្នុងការកែលម្អប្រព័ន្ធការពិនិត្យបញ្ជីឯកសារបញ្ជាក់អត្តសញ្ញាណ។ ក្រុមការងារក៏បានធ្វើសិក្ខាសាលាពិភាក្សាទាក់ទិននឹងការចុះឈ្មោះអ្នកបោះឆ្នោត បញ្ជីបោះឆ្នោត និងការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោតប្រចាំឆ្នាំ មានអនុសាសន៍ជាច្រើនត្រូវបានពិភាក្សា។ មានការវាយតម្លៃខ្ពស់ចំពោះក្រុមការងារក្រសួងមហាផ្ទៃ និងគជប ដែលស្នើលទ្ធភាពអនុវត្តអនុសាសន៍ខ្លះ បង្កើនពេលវេលាសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ការកែលម្អនីតិវិធី នៃការចេញឯកសារបញ្ជាក់អត្តសញ្ញាណ (ទម្រង់ ១០១៨) និងឯកសារបញ្ជាក់ការស្នាក់នៅ និងពន្យាសុពលភាពប័ណ្ណដែលផុតកាលកំណត់អាចប្រើប្រាស់ដើម្បីបោះឆ្នោតបានរហូតដល់ឆ្នាំ ២០១៣។ ទោះបីជាយ៉ាងណា វេទិកាស្តីពីការបោះឆ្នោត និងប្រជាធិបតេយ្យ ប្រជាពលរដ្ឋបានផ្តល់យោបល់ថា អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ គួរក្លាយជាឯកសារអចិន្ត្រៃយ៍។ ប្រទេសម៉ាឡេស៊ី ជាឧទាហរណ៍ ក្នុងការផ្តល់អត្តសញ្ញាណប័ណ្ណអចិន្ត្រៃយ៍ដល់ប្រជាពលរដ្ឋ។

ក្រុមការងារចម្រុះ (គជប និងក្រសួងមហាផ្ទៃ) លើកឡើងលទ្ធភាពក្នុងការកែលម្អទម្រង់បញ្ជាក់អត្តសញ្ញាណ (ទម្រង់ ១០១៨) និងការស្នាក់នៅដែលអាចមានការគ្រប់គ្រងមួយឲ្យច្បាស់លាស់ជាងមុន រួមមាន លេខរៀង រូបថត និងហើយបិតផ្សាយព័ត៌មាន ឬរបាយការណ៍អំពីការចេញឯកសារនេះ។ ទោះបីជាយ៉ាងណា ខុមហ្វ្រែល ផ្តល់យោបល់ថា ឯកសារបញ្ជាក់អត្តសញ្ញាណបណ្តោះអាសន្ន គួរតែប្តូរទម្រង់រូបរាង ទៅជាប័ណ្ណបោះឆ្នោតបណ្តោះអាសន្ន (ដូចប័ណ្ណបោះឆ្នោត)។ ប័ណ្ណនេះ អាចប្រើប្រាស់សម្រាប់ការបោះឆ្នោត ២ ដង គឺការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។ ចំនួនអ្នកបោះឆ្នោតដែលគ្មានអត្តសញ្ញាណប័ណ្ណខ្មែរ អាចដឹងតាមរយៈការផ្ទៀងផ្ទាត់ទៅលើទិន្នន័យអ្នកបោះ-ឆ្នោត។

ជាសរុប កំណែទម្រង់ការចុះឈ្មោះបោះឆ្នោត ការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកបោះ-ឆ្នោត (រួមទាំងការលុបឈ្មោះអ្នកបោះឆ្នោត) និងការផ្តល់ឯកសារបញ្ជាក់អត្តសញ្ញាណ (អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ) ពិតជា កិច្ចការចាំបាច់បំផុត ដើម្បីបង្កើនការគោរពសិទ្ធិ និងធានាសិទ្ធិចូលរួមក្នុងការបោះឆ្នោត និងការបោះឆ្នោតមួយដោយសេរី និងយុត្តិធម៌៕